# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម

លេខ ០៩៥ ព.ណ.ក.ស.រ.ស.ប្រក

# ប្រកាស
## ស្តីពី
## ការអនុវត្តមិនសុចរិតក្នុងធុរកិច្ច
## ពាក់ព័ន្ធនឹងការផ្សាយពាណិជ្ជកម្មនិងការជំរុញការលក់

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៦ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់
- បានឃើញអនុក្រឹត្យលេខ៣៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ១៣៥ អនក្រ.បក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់
- បានឃើញអនុក្រឹត្យលេខ១៩ អនក្រ.បក ចុះថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការកែសម្រួលអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់
- បានឃើញអនុក្រឹត្យលេខ២៣២ អនក្រ.បក ចុះថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០២២ ស្តីពីការគ្រប់គ្រង ការផ្សាយពាណិជ្ជកម្មលើផលិតផលទំនិញនិងសេវា
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម

## សម្រេច

**ប្រការ១.-**

ប្រកាសនេះកំណត់អំពីការអនុវត្តមិនសុចរិតមួយចំនួនក្នុងធុរកិច្ច ដែលមិនមានចែងក្នុងច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ ពាក់ព័ន្ធនឹងការផ្សាយពាណិជ្ជកម្មនិងការជំរុញការលក់ ដើម្បីការពារសិទ្ធិ និងផលប្រយោជន៍របស់អ្នកប្រើប្រាស់។



១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
លេខទំនាក់ទំនង៖ ១២៦៦
អ៊ីមែល៖ cabinet.info@moc.gov.kh

**ប្រការ២.-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះបុគ្គលទាំងឡាយដែលធ្វើធុរកិច្ចផ្គត់ផ្គង់ និងផ្សព្វផ្សាយផលិតផលទំនិញ និងសេវា តាមរយៈការសន្យា ការផ្សព្វផ្សាយ ឬការអះអាង ដែលមិនពិតឬបំភាន់ តាមគ្រប់ប្រភេទ គ្រប់ទម្រង់ និងគ្រប់មធ្យោបាយ រួមទាំងមធ្យោបាយឌីជីថល នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៣.-**

វាក្យសព្ទសំខាន់ៗមួយចំនួនដែលប្រើក្នុងប្រកាសនេះ ត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

១. **ការផ្សព្វផ្សាយ** សំដៅដល់ការផ្សាយពាណិជ្ជកម្ម និងការជំរុញការលក់ ដោយផ្សាយជាសាធារណៈ ឬផ្សាយទៅកាន់ក្រុមណាមួយ ឬបុគ្គលណាមួយ ក្នុងចំណោមសាធារណជន តាមគ្រប់ទម្រង់ និងគ្រប់មធ្យោបាយ រួមទាំងមធ្យោបាយឌីជីថល ក្នុងគោលបំណងជំរុញការផ្គត់ផ្គង់ផលិតផលទំនិញនិងសេវា ការលក់ ឬការផ្តល់សិទ្ធិប្រត្យក្សលើអចលនទ្រព្យ។

២. **ការជំរុញការលក់** សំដៅដល់សកម្មភាពដែលទាក់ទាញការទិញឱ្យបានឆាប់រហ័ស ជាអាទិ៍ ការលក់បញ្ចុះថ្លៃ ការលក់បញ្ចុះថ្លៃពិសេស ការលក់លាងឃ្លាំង ការផ្តល់រង្វាន់ឬវត្ថុអនុស្សាវរីយ៍ ការតាំងពិព័រណ៍ ការចាប់ឆ្នោតផ្សងសំណាង ការឧបត្ថម្ភកម្មវិធី ការលក់ផលិតផលទំនិញនិងសេវាដោយភ្ជាប់ទំនិញឬសេវាដែលមិនមានតម្រូវការ។

៣. **ការលក់បញ្ចុះថ្លៃ** សំដៅដល់ការជំរុញការលក់ផលិតផលទំនិញនិងសេវា ដោយកំណត់ថ្លៃទាប ជាងថ្លៃលក់ធម្មតាឬថ្លៃលក់មុនបញ្ចុះថ្លៃក្នុងរយៈពេលជាក់លាក់។

៤. **ការលក់លាងឃ្លាំង** សំដៅដល់ការជំរុញការលក់ផលិតផលទំនិញដោយថ្លៃទាបជាងថ្លៃលក់ធម្មតា ឬថ្លៃលក់មុនលក់លាងឃ្លាំង និងមានចំនួនកំណត់ ដើម្បីបញ្ចប់ស្តុកទំនិញនៅសល់។

៥. **ការលក់បញ្ចុះថ្លៃពិសេស** សំដៅដល់ការជំរុញការលក់ច្រើនលើកតាមរយៈការផ្តល់បណ្ណសមាជិក ឬបណ្ណសន្សំពិន្ទុ ក្នុងគោលបំណងផ្តល់តម្លៃតបស្នងឬផលប្រយោជន៍ជាក់លាក់ណាមួយដល់អតិថិជន។

៦. **ការសន្យា** សំដៅដល់ការដាក់លក្ខខណ្ឌរបស់ម្ចាស់ផលិតផលទំនិញឬសេវា ជូនទៅអតិថិជនរបស់ខ្លួន តាមរយៈការផ្សព្វផ្សាយដោយផ្ទាល់មាត់ ឬលាយលក្ខណ៍អក្សរ ឬដោយទម្លាប់ ដើម្បីលក់និងជំរុញការលក់។

៧. **រង្វាន់** សំដៅដល់រូបិយវត្ថុ វត្ថុអនុស្សាវរីយ៍ ផលិតផលទំនិញ សេវា ជាអាទិ៍ សម្រាប់ភ្ជាប់ជាមួយផលិតផលទំនិញ និងសេវា ឬផ្តល់ឱ្យដោយឥតគិតថ្លៃ ឬផ្តល់ជាអំណោយ ឬផ្តល់ឱ្យតាមរយៈការចាប់ឆ្នោតផ្សងសំណាង។

៨. **ស្លាកផ្សាយពាណិជ្ជកម្ម** សំដៅដល់ខិត្តប័ណ្ណ បដា ប៉ាណូ អាហ្វីស ផ្ទាំង LED បណ្ណផ្សព្វផ្សាយ និងសម្ភារផ្សេងៗទៀត ដែលត្រូវបានប្រើប្រាស់សម្រាប់ការផ្សាយពាណិជ្ជកម្មនិងការជំរុញការលក់។

**ប្រការ៤.-**

បុគ្គលធ្វើធុរកិច្ចដែលផ្សាយពាណិជ្ជកម្មមានភ្ជាប់រង្វាន់ ត្រូវផ្តល់នូវផែនការផ្តល់រង្វាន់ ឯកសារ ឬព័ត៌មានស្តីពីអត្តសញ្ញាណអ្នកឈ្នះរង្វាន់និង/ឬអ្នកត្រូវរង្វាន់ ឬឯកសារពាក់ព័ន្ធផ្សេងៗទៀត ឱ្យបានទាន់ពេលវេលា តាមការតម្រូវរបស់មន្ត្រីស៊ើបអង្កេតនៃអគ្គនាយកដ្ឋាន ក.ប.ប.។

ផែនការផ្តល់រង្វាន់ ត្រូវបញ្ជាក់ជាអាទិ៍ ផលិតផលទំនិញនិងសេវាសរុបដែលមានរង្វាន់ ប្រភេទរង្វាន់ ចំនួនរង្វាន់សរុប លក្ខខណ្ឌ និងសុពលភាពនៃការផ្តល់រង្វាន់។

ឯកសារឬព័ត៌មានស្តីពីអត្តសញ្ញាណអ្នកឈ្នះរង្វាន់និង/ឬអ្នកត្រូវរង្វាន់ ត្រូវបញ្ជាក់ជាអាទិ៍ ឈ្មោះ ភេទ អាសយដ្ឋាន លេខអត្តសញ្ញាណប័ណ្ណ លេខទូរសព្ទ ថ្ងៃខែឆ្នាំផ្តល់រង្វាន់ ប្រភេទរង្វាន់ និងទីតាំងផ្តល់រង្វាន់។

**ប្រការ៥.-**

ត្រូវហាមឃាត់ការអនុវត្តមិនសុចរិតពាក់ព័ន្ធនឹងការផ្តល់រង្វាន់៖

- មិនផ្តល់រង្វាន់ ផ្តល់រង្វាន់មិនគ្រប់ចំនួនតាមផែនការ និងរង្វាន់មានតម្លៃមិនសមមូលតាមផែនការ លើកលែងមានកត្តាតងផ្ទុយណាមួយដែលអាចទទួលយកបាន
- ផ្តល់ឯកសារឬព័ត៌មានស្តីពីអត្តសញ្ញាណអ្នកឈ្នះរង្វាន់និង/ឬអ្នកត្រូវរង្វាន់ ដោយក្លែងបន្លំ មិនពិត ភូតកុហក និងមិនផ្តល់ឯកសារពាក់ព័ន្ធផ្សេងៗ តាមការតម្រូវរបស់មន្ត្រីស៊ើបអង្កេតនៃអគ្គនាយកដ្ឋាន ក.ប.ប.។

**ប្រការ៦.-**

ត្រូវហាមឃាត់សកម្មភាពនៃការអនុវត្តមិនសុចរិតផ្សេងទៀត ពាក់ព័ន្ធនឹងការផ្សាយពាណិជ្ជកម្មនិងការជំរុញការលក់ ជាអាទិ៍៖

- យកអនីតិជនមកប្រគល់ទទួលរង្វាន់ និងផ្សាយពាណិជ្ជកម្មពាក់ព័ន្ធនឹងផលិតផលគ្រឿងស្រវឹង ភេសជ្ជៈប៉ូវកម្លាំង ឬក្នុងករណីហាមឃាត់ដោយបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត
- ស្លាកយីហោ ស្លាកផ្សាយពាណិជ្ជកម្មគ្រប់ប្រភេទដែលមិនមានអក្សរខ្មែរ ឬពុម្ពអក្សរខ្មែរមិននៅលើពុម្ពអក្សរបរទេសនិង/ឬមិនធំជាងពុម្ពអក្សរបរទេសពីរដង
- ផ្សព្វផ្សាយលក់ផលិតផលទំនិញនិងសេវា ដែលលិខិតបទដ្ឋានគតិយុត្តបានហាមឃាត់ធ្វើពាណិជ្ជកម្ម និង/ឬផ្សាយពាណិជ្ជកម្ម
- ផ្សព្វផ្សាយលក់ផលិតផលទំនិញនិងសេវា ដោយមិនបង្ហាញនូវព័ត៌មានអប្បបរមាតាមបទប្បញ្ញត្តិ ដែលកំណត់ដោយក្រសួង ស្ថាប័ន និងបញ្ញត្តិករមានសមត្ថកិច្ចពាក់ព័ន្ធ
- យកខ្លឹមសារ ទម្រង់ នៃអត្ថបទឬស្ពតផ្សាយពាណិជ្ជកម្មរបស់បុគ្គលណាម្នាក់ដោយមិនទទួលបានការយល់ព្រមពីបុគ្គលនោះ មកធ្វើការផ្សព្វផ្សាយលក់ផលិតផលទំនិញនិងសេវា
- បង្ខំបុគ្គលដទៃឱ្យធ្វើការផ្សព្វផ្សាយលក់ផលិតផលទំនិញនិងសេវាជំនួសខ្លួន ដោយមិនមានការស្ម័គ្រចិត្ត
- មិនផ្តល់កម្រៃជើងសារ តម្លៃតបស្នងនិង/ឬអត្ថប្រយោជន៍ផ្សេងទៀត តាមការសន្យាដែលធ្វើឡើងដោយបុគ្គលធ្វើធុរកិច្ច។

**ប្រការ៧.-**

បុគ្គលធ្វើធុរកិច្ចផ្គត់ផ្គង់ផលិតផលទំនិញនិងសេវាក្នុងកំលុងពេលលក់បញ្ចុះថ្លៃ ត្រូវបង្ហាញជាសាធារណៈ នូវ៖

- ថ្លៃលក់មុនបញ្ចុះថ្លៃ
- ភាគរយបញ្ចុះថ្លៃ ឬថ្លៃថ្មីត្រូវលក់បញ្ចុះថ្លៃ
- កាលបរិច្ឆេទច្បាស់លាស់ ពីថ្ងៃចាប់ផ្តើម រហូតដល់ថ្ងៃបញ្ចប់នៃការលក់បញ្ចុះថ្លៃ។

**ប្រការ៨.-**

បុគ្គលធ្វើធុរកិច្ចផ្គត់ផ្គង់ផលិតផលទំនិញក្នុងកំលុងពេលលក់លាងឃ្លាំង ត្រូវបង្ហាញជាសាធារណៈ នូវ៖

- ថ្លៃលក់មុនលក់លាងឃ្លាំង
- ភាគរយបញ្ចុះថ្លៃ ឬថ្លៃថ្មីត្រូវលក់លាងឃ្លាំង
- កាលបរិច្ឆេទច្បាស់លាស់ ពីថ្ងៃចាប់ផ្តើម រហូតដល់ថ្ងៃបញ្ចប់នៃការលក់លាងឃ្លាំងនិង/ឬទំនិញអស់ពីស្តុក។

**ប្រការ៩.-**

បុគ្គលធ្វើធុរកិច្ចផ្គត់ផ្គង់ផលិតផលទំនិញនិងសេវាក្នុងកំលុងពេលលក់បញ្ចុះថ្លៃពិសេស ត្រូវបង្ហាញជាសាធារណៈ នូវ៖

- ថ្លៃនៃការដាក់បង្ហាញដំបូង

- តម្លៃតបស្នង ឬអត្ថប្រយោជន៍នៃការចូលជាសមាជិក
- សុពលភាពនៃសមាជិកភាព
- លក្ខខណ្ឌផ្សេងៗដែលជាការតម្រូវចាំបាច់។

**ប្រការ១០.-**

បុគ្គលធ្វើធុរកិច្ចផ្គត់ផ្គង់ផលិតផលទំនិញនិងសេវា ដោយមានភ្ជាប់ផលិតផលទំនិញនិងសេវាបន្ថែមផ្សេងទៀត ដែលលើសពីតម្រូវការ (ជាកញ្ចប់) ត្រូវបង្ហាញជាសាធារណៈ នូវ៖

- ផលិតផលទំនិញនិងសេវាដែលត្រូវភ្ជាប់មកជាមួយ
- ចំនួនផលិតផលទំនិញនិងសេវាដែលត្រូវភ្ជាប់មកជាមួយ
- ថ្លៃសរុបត្រូវលក់។

**ប្រការ១១.-**

រាល់ការចាប់ឆ្នោតផ្សងសំណាង ដើម្បីផ្តល់រង្វាន់ជូនដល់អ្នកប្រើប្រាស់ដោយបុគ្គលធ្វើធុរកិច្ច ត្រូវ៖

- ប្រព្រឹត្តទៅតាមកាលបរិច្ឆេទដែលបានកំណត់
- រៀបចំជាសាធារណៈ
- មានតម្លាភាព សមភាព យុត្តិធម៌ ចំពោះអ្នកប្រើប្រាស់
- ធានាការផ្តល់រង្វាន់ពិតប្រាកដដល់អ្នកប្រើប្រាស់។

**ប្រការ១២.-**

បុគ្គលធ្វើធុរកិច្ចផ្គត់ផ្គង់ផលិតផលទំនិញ និងសេវាត្រូវបិទស្លាកថ្លៃជាប្រាក់រៀលលើគ្រប់មុខផលិតផលទំនិញនិងសេវា ដែលតាំងលក់នៅក្នុងផ្សារទំនើប ម៉ាត មីនីម៉ាត អាគារលក់ផលិតផល និងស្ថានីយ ដេប៉ូលក់ ប្រេងឥន្ធនៈនិង/ឬឧស្ម័ន លើកលែងតែតូប ឬបញ្ចរលក់ទំនិញបន្ទាប់បន្សំ។

ការបិទស្លាកថ្លៃជារូបិយប័ណ្ណបរទេសអាចប្រព្រឹត្តទៅបាន ប្រសិនបើមានការអនុញ្ញាតដោយក្រសួង ស្ថាប័ន ឬអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ស្របទៅតាមច្បាប់ឬបទប្បញ្ញត្តិដែលមានជាធរមាន។

ការបិទស្លាកថ្លៃ ត្រូវសរសេរជាអក្សរខ្មែរនៅពីមុខ ឬនៅពីលើ និងអក្សរបរទេសនៅបន្ទាប់ ឬខាងក្រោម។

**ប្រការ១៣.-**

ត្រូវហាមឃាត់ការផ្សព្វផ្សាយ ដើម្បីលក់ផលិតផលទំនិញនិងសេវាដែលមានភ្ជាប់សេចក្តីបរិយាយពាណិជ្ជកម្មមិនពិតឬមានលក្ខណៈ ជាអាទិ៍៖

- ជំរុញឱ្យអនីតិជនគិត អនុវត្តតាម និយាយ ឬបញ្ចេញកាយវិការផ្ទុយពីទំនៀមទម្លាប់ ប្រពៃណី និងសីលធម៌ ជះឥទ្ធិពលអវិជ្ជមានដល់សុខភាព សុវត្ថិភាព ឬការអភិវឌ្ឍធម្មជាតិរបស់អនីតិជន
- ប្រើពាក្យឬឃ្លា ជាអាទិ៍ ល្អបំផុត តែម្នាក់ លេខមួយ លើសគេ គ្មានគូប្រៀប ឬពាក្យដែលមានអត្ថន័យ ស្រដៀងគ្នា ដោយគ្មានឯកសារត្រឹមត្រូវ ដែលបានបញ្ជាក់ដោយក្រសួង ស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ
- ប្រើពាក្យឬឃ្លា ជាអាទិ៍ គាស់ឈ្នះៗ កោសឈ្នះៗ ទិញឈ្នះៗ បើកឈ្នះៗ កាន់តែគាស់កាន់តែឈ្នះ គាស់ច្រើនឈ្នះច្រើន កាន់តែកោសកាន់តែឈ្នះ ទិញ១ ថែម១ ទិញថែមៗ ឬប្រើពាក្យ ឬឃ្លា ដែលមានអត្ថន័យប្រហាក់ប្រហែល ដោយបុគ្គលធ្វើធុរកិច្ចពុំបានបញ្ជាក់ជូនអ្នកប្រើប្រាស់អំពីប្រភេទផលិតផលទំនិញនិងសេវា ដែលត្រូវផ្តល់ឱ្យ



១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
លេខទំនាក់ទំនង៖ ១២៦៦
អ៊ីមែល៖ cabinet.info@moc.gov.kh

- ប្រើពាក្យសម្តី សំណេរ ឬរូបភាពនានា ដែលមានលក្ខណៈភូតកុហក បំភាន់ ឬពង្វាងការពិត អាសអាភាស ស្រើបស្រាល ពាក្យអសុរោះ
- ប្រើអត្ថបទឬស្លាក ដែលមានខ្លឹមសារមិនស្របតាមលិខិតបញ្ជាក់អនុលោមភាពរបស់អគ្គនាយកដ្ឋាន ក.ប.ប. នៃក្រសួងពាណិជ្ជកម្ម
- ផ្តល់ឬបញ្ជាបុគ្គលណាម្នាក់ឱ្យធ្វើការផ្សព្វផ្សាយភូតកុហកថា ខ្លួនបានទទួលរង្វាន់ ឬផលប្រយោជន៍ ផ្សេងទៀត ពីផលិតផលទំនិញនិងសេវាណាមួយ
- ប្រៀបធៀបផលិតផលទំនិញនិងសេវារបស់ខ្លួន ក្នុងចេតនាបង្អាប់ឬប៉ះពាល់ជាមួយនឹងផលិតផលទំនិញនិងសេវារបស់បុគ្គលផ្សេងទៀត
- សំដែងកាយវិការណាមួយដែលធ្វើឱ្យប៉ះពាល់ដល់ផលិតផលទំនិញនិងសេវារបស់បុគ្គលផ្សេងទៀត
- បំពានបទប្បញ្ញត្តិពាក់ព័ន្ធជាធរមានផ្សេងទៀត។

**ប្រការ១៤.-**

ត្រូវទទួលពិន័យអន្តរការណ៍តាមមាត្រា៤៤ នៃច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ ចំពោះបុគ្គលណាដែលប្រព្រឹត្ត អំពើល្មើសនឹងប្រការ៤ ប្រការ៥ ប្រការ៦ ប្រការ៧ ប្រការ៨ ប្រការ៩ ប្រការ១០ ប្រការ១១ និងប្រការ១២ នៃប្រកាសនេះ។

**ប្រការ១៥.-**

ត្រូវទទួលពិន័យអន្តរការណ៍តាមមាត្រា៤៥ នៃច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ ចំពោះបុគ្គលណាដែលប្រព្រឹត្ត អំពើល្មើសនឹងប្រការ១៣ នៃប្រកាសនេះ។

**ប្រការ១៦.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១៧.-**

សមាសភាពគណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់ នាយកខុទ្ទកាល័យ ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួល បន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ គ្រប់អគ្គនាយក នៃអគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធានគ្រប់អង្គភាពចំណុះក្រសួងពាណិជ្ជកម្ម ត្រូវទទួលបន្ទុកអនុវត្តតាម ប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ៤កើត ខែចេត្រ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១២ ខែមេសា ឆ្នាំ២០២៤

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**និងជាប្រធានគណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់**

ព្រះរាជាណាចក្រកម្ពុជា * ក្រសួងពាណិជ្ជកម្ម *

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ១៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ចម_និម្មល**



១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
លេខទំនាក់ទំនង៖ ១២៦៦
អ៊ីមែល៖ cabinet.info@moc.gov.kh